# សាំយូអែល និង ផ្កាយ



ជាច្រើនឆ្នាំកន្លងទៅហើយ កាលពីបុរាណ នៅទីដីសែនឆ្ងាយឆ្លងកាត់សមុទ្រ មានបុរសម្នាក់ឈ្មោះសាំយូអែលបានផ្ដល់ការព្យាករណ៍ ។



លោកបានប្រាប់ប្រជាជនអំពីការណ៍ជាច្រើនទាក់ទងនឹងការប្រសូត្ររបស់ព្រះអង្គសង្គ្រោះ ។ លោកបាននិយាយទៅកាន់ពួកគេអំពីព្រះយេស៊ូវ គ្រីស្ទ និងរបៀបដែលទ្រង់យាងមកផែនដី ។



ប្រជាជនមិនបានស្ដាប់លោកទេ ។ ដួងចិត្តរបស់ពួកគេពេញទៅដោយភាពសង្ស័យ ។ ដូច្នេះពួកគេបានចាប់សាំយូអែលទៅឯទ្វារក្រុង ហើយបោះគាត់ចេញ ។



ប៉ុន្តែសាំយូអែលមិនចុះចាញ់ឡើយ ។ លោកត្រូវតែប្រាប់ឲ្យពួកគេបានដឹង ។ លោកបានឡើងលើកំផែងទីក្រុង ហើយស្រែកប្រាប់ពួកគេដែលនៅខាងក្រោម ។



« ត្បិតទៅប្រាំឆ្នាំទៀត ព្រះអម្ចាស់នឹងយាងមក គឺជាយប់ដែលមានផ្កាយបញ្ចេញពន្លឺជាច្រើន ដើម្បីសង្គ្រោះមនុស្សលោកពីអំពើបាបរបស់ពួកគេ និងប្រទានពន្លឺរបស់ទ្រង់ដល់ពិភពលោក » ។



« ហើយត្បិតអីនៅរយៈពេលប្រាំឆ្នាំហើយនៅឆ្ងាយតែគ្រានោះពេលព្រះអាទិត្យលិចពុំមានភាពងងឹតឡើយ ប៉ុន្តែភ្លឺដូចជាពេលថ្ងៃ » ។



ប្រជាជនមានចិត្តក្ដៅក្រហាយ ហើយទន្ទ្រាំជើង ។ ពួកគេពោលថា គ្មានព្រះគ្រីស្ទនឹងយាងមកទេ ។ ពួកគេបានគប់ដុំថ្ម ។ ពួកគេបានបាញ់ព្រួញ ។ ពួកគេគ្រប់គ្នាបាញ់និងគប់មិនចំគាត់ទេ ។



មនុស្សស្មោះត្រង់បានរង់ចាំ ទាំងត្រេកអរត្រេកអរ សង្ឃឹមថាពួកគេនឹងឃើញ—ផ្កាយពន្លឺ សេចក្ដីសន្យាដែលមានតម្លៃជាងមាស ។



ប្រាំឆ្នាំក្រោយមក នៅភូមិបេថ្លេហិម ព្រះគ្រីស្ទបានផ្ទំនៅក្នុងស្នូកក្នុងក្រោល ។ ពួកគេបានឃើញពន្លឺហើយបានដឹងថា ទ្រង់បានយាងមកជាព្រះអង្គសង្គ្រោះជាព្រះអម្ចាស់របស់ពួកគេគ្រប់រូប ។

ហើយដូចដែលហេតុការណ៍បានកើតឡើងជានិច្ចថា នៅពេលដែលព្យាការីមានភាពអង់អាចក្លាហាន ព្រះអម្ចាស់តែងតែបំពេញសេចក្ដីសន្យារបស់ទ្រង់ជានិច្ច ដូចសាំយូអែលពីបុរាណបានធ្វើ ។ ●

អ្នកអាចមើលវីដេអូ នៅ **bit.ly/3cz7F2j** ។ ឬអានដំណើររឿងនៅក្នុង ហេលេមិន ១៣–១៥; នីហ្វៃទី ៣ ១:១៣–១៥, ២១ ។

